- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-** ត្រូវបានបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី៩ ដែលនឹងប្រារព្ធធ្វើនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២-ឯកឧត្តម **ម៉ៅ ថូរ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាននិងជាឧត្តមមន្ត្រី |
| ៣-ឯកឧត្តម **វង្សី វិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៥-លោកជំទាវ **តឹករ៉េត កំរេង** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិកា |
| ៦-ឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៧-ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋលេខាធិការរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៨-ឯកឧត្តម **ហេង តៃគ្រី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៩-ឯកឧត្តម **ថៃ នរៈសត្យា** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១០-ឯកឧត្តម **ទ៉េង សុធី** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១-ឯកឧត្តម **សុខ សុភ័ក្រ** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២-ឯកឧត្តម **ពេជ ឫទ្ធី** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣-ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |
| ១៤-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៥-ឯកឧត្តម **ឃឹម ប៊ុនសុង** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ១៦-ឯកឧត្តម **ភឹម គុណាវឌ្ឍន៍** | អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា ក្រសួងព័ត៌មាន | សមាជិក |
| ១៧-ឯកឧត្តម **ស៊ាង ថៃ** | អគ្គនាយកជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៨-ឯកឧត្តម **អ៊ុក ទី** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៩-ឯកឧត្តម **ស៊ឹម សុខខេង** | អគ្គនាយកពាណិជ្ជកម្មអន្តរជាតិក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២០-លោក **ណុប សោភ័ណតារា** | ប្រធាននាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិកក្រសួងពាណិជ្ជកម្ម | សមាជិក |

**ប្រការ២**._គណៈកម្មការរៀបចំកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី៩ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំកម្មវិធីប្រជុំ និងចាត់ចែងការងារពិធីការឲ្យបានសមស្រប និងថ្លៃថ្នូរ
- សម្របសម្រួល និងរៀបចំការពារសន្តិសុខជូនគណៈប្រតិភូ ដែលអញ្ជើញចូលរួមកិច្ចប្រជុំឲ្យមានសុវត្ថិភាពល្អ
- សិក្សា ស្រាវជ្រាវ និងចងក្រងឯកសារសំខាន់ៗសម្រាប់កិច្ចប្រជុំ
- រៀបចំមន្ទីរពេទ្យ គ្រូពេទ្យប្រចាំការ និងសង្គ្រោះបន្ទាន់ នៅតាមគោលដៅចាំបាច់
- ចាត់ចែងការសម្តែងសិល្បៈប្រពៃណីជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ
- សម្របសម្រួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយព័ត៌មានជុំវិញការរៀបចំកិច្ចប្រជុំ
- សម្របសម្រួល និងចាត់ចែងកិច្ចការទូទៅពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំខាងលើ ឲ្យទទួលបានលទ្ធផលល្អប្រសើរ
- រៀបចំគម្រោងចំណាយសម្រាប់ការរៀបចំកិច្ចប្រជុំខាងលើ រួចលើកសំណើសុំថវិកាពីរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការចាំបាច់។

**ប្រការ៣**._ ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី៩ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងទៀត តាមការចាំបាច់ ដើម្បីធានាឲ្យការរៀបចំកិច្ចប្រជុំទទួលបានលទ្ធផលល្អប្រសើរ។

**ប្រការ៤.-** សមាជិកគណៈកម្មការរៀបចំកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាមលើកទី៩ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៥.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អភិបាលនៃគណៈអភិបាលខេត្តសៀមរាប រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
លេខ...៩៤៦...សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

## គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦-២០១៩
- បានឃើញផែនការអន្តរស្ថាប័នលេខ ០០៩ ផ.ក/១៦ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩
- តាមការចាំបាច់របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ។

## ស ម្រេ ច

**ប្រការ ១** : ត្រូវបានបង្កើតលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ បោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦-២០១៩ ដែលសមាសភាពមានដូចតទៅ ៖

១- ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ ប្រធាន

| | | | | |
|---|---|---|---|---|
| ២- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **មាស សុផា** | អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងគោក | អនុប្រធាន |
| ៣- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **សៅ សុខា** | អគ្គមេបញ្ជាការរង មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៤- | ឯកឧត្តមនាយឧត្តមនាវី | **ទៀ វិញ** | មេបញ្ជាការកងទ័ពជើងទឹក | អនុប្រធាន |
| ៥- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **ម៉ៅ ម៉ុនណារិន** | អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៦- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **ស៊ីម សំណាង** | មេបញ្ជាការកងទ័ពជើងអាកាស | សមាជិក |
| ៧- | ឯកឧត្តមឧត្តមសេនីយ៍ឯក | **ង៉ោ ឥត្ថិ** | អគ្គលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **គៀត ចំនួនថារិទ្ធ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៩- | ឯកឧត្តមនាយឧត្តមសេនីយ៍ | **ឆៃ ស៊ីណារិទ្ធ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១០- | ឯកឧត្តមឧត្តមសេនីយ៍ឯក | **ម៉ៅ សុផាន់** | នាយរងសេនាធិការចម្រុះ មេបញ្ជាការកងពលតូចលេខ៧០ | សមាជិក |
| ១១- | ឯកឧត្តមឧត្តមសេនីយ៍ឯក | **ខៀវ ពិសេន** | មេបញ្ជាការរង នាយសេនាធិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១២- | ឯកឧត្តមឧត្តមសេនីយ៍ឯក | **ព្រហ្ម ឌិន** | មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគពិសេស | សមាជិក |
| ១៣- | ឯកឧត្តមឧត្តមសេនីយ៍ឯក | **ហួត ឈាង** | មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី១ | សមាជិក |
| ១៤- | ឯកឧត្តមឧត្តមសេនីយ៍ឯក | **ជឿន សុវណ្ណថា** | មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី២ | សមាជិក |
| ១៥- | ឯកឧត្តមឧត្តមសេនីយ៍ឯក | **យឿង សុខុន** | មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៣ | សមាជិក |
| ១៦- | ឯកឧត្តមឧត្តមសេនីយ៍ឯក | **ជា ម៉ន** | មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៤ | សមាជិក |
| ១៧- | ឯកឧត្តមឧត្តមសេនីយ៍ឯក | **ម៉ុន សេង** | មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៥ | សមាជិក |
| ១៨- | ឯកឧត្តម | **ឆេស វុទ្ធាផល** | អគ្គនាយករងនៃអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម-បាតុកម្មនៅតាមគ្រប់មុខសញ្ញា(គ.ក.ប) នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

១៩- ឯកឧត្តមឧត្តមសេនីយ៍ឯក **ឆាយ គីមខឿន** ប្រធានសេនាធិការដ្ឋាន សមាជិក

២០- ឯកឧត្តមឧត្តមសេនីយ៍ឯក **ឌី ទិដ្ឋា** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ សមាជិក

២១- ឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ិន បូរ៉ា** ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ សមាជិក

២២- ឯកឧត្តមឧត្តមសេនីយ៍ឯក **សេក ត្នូមី** ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ សមាជិក

២៣- ឯកឧត្តមឧត្តមសេនីយ៍ឯក **សារ៉ាន់ គំសត់** ប្រធាននាយកដ្ឋានសរុបផែនការ សមាជិក

២៤- ឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ី សុខឃី** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្មនិងឧក្រិដ្ឋកម្មឆ្លងដែន សមាជិក

២៥- ឯកឧត្តមឧត្តមសេនីយ៍ឯក **សឿន សេន** ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង សមាជិក

២៦- លោកឧត្តមសេនីយ៍ទោ **សុខ ខេមរិន** ប្រធាននាយកដ្ឋានន/បព្រហ្មទណ្ឌ សមាជិក

២៧- លោកឧត្តមសេនីយ៍ទោ **មិន សុវណ្ណា** ប្រធាននាយកដ្ឋានវិទ្យុទាក់ទង សមាជិក

២៨- លោកឧត្តមសេនីយ៍ទោ **ឡោ សុឡេខ** ស្នងការនៃស្នងការដ្ឋានហិរញ្ញវត្ថុ និងភស្តុភារ សមាជិក

២៩- លោក **ឈួត សារគល** ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៣០- លោក **យុន ហោខ** ប្រធាននាយកដ្ឋានវិភាគគម្រោងវិនិយោគនិងការលើកទឹកចិត្ត នៃគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៣១- លោក **ម៉ី ម៉ុនឈី** ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងពាណិជ្ជកម្ម សមាជិក

៣២- លោក **ម៉ូ បូនី** អនុប្រធាននាយកដ្ឋានថវិកានីយកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៣៣-អស់លោកអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត សមាជិក

**ប្រការ ២** : លេខាធិការដ្ឋានមានភារកិច្ច ដូចតទៅ ៖

ជួយប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់របស់យន្តការរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោត និងភ្នាក់ងារសន្តិសុខបោះឆ្នោត ផ្អែកតាមផែនការអន្តរស្ថាប័នលេខ ០០៩ ផ.ក/១៦ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៦ រវាងក្រសួងមហាផ្ទៃក្រសួងការពារជាតិនិង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦-២០១៩ ។

- ផ្សព្វផ្សាយផែនការ ផែនការសកម្មភាព បទបញ្ជានិងសេចក្តីណែនាំផ្សេងៗស្តីពីកិច្ចការការពារសន្តិសុខ
- បោះឆ្នោត ដល់ក្រសួង /ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ពិសេសយន្តការរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោត និងភ្នាក់ងារសន្តិសុខបោះឆ្នោត ព្រមទាំងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីជ្រួតជ្រាប និងសហការអនុវត្ត ។
- ប្រមូលផ្តុំព័ត៌មានជុំវិញស្ថានការណ៍សន្តិសុខបោះឆ្នោតពីបណ្តាក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ យន្តការរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោត និងធ្វើរបាយការណ៍ជូនប្រធានគណៈកម្មការសន្តិសុខអចិន្ត្រៃយ៍ និងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងមានវិធានការដោះស្រាយឲ្យបានទាន់ពេលវេលា ។
- ត្រូវរៀបចំសន្និបាត ឬកិច្ចប្រជុំការងារផ្សព្វផ្សាយរបស់គណៈកម្មការសន្តិសុខអចិន្ត្រៃយ៍ ដោយត្រូវធ្វើលិខិតអញ្ជើញគ្រប់សមាសភាពរបស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ និងភាគីពាក់ព័ន្ធដើម្បីចូលរួមផ្អែកលើគោលការណ៍ដែលប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ បានសម្រេច ។
- លើកគម្រោងសុំថវិកាសម្រាប់បំប៉នដល់ភ្នាក់ងារសន្តិសុខបោះឆ្នោត ថវិកាសម្រាប់ការផ្គត់ផ្គង់ប្រេងឥន្ធនៈដល់មធ្យោបាយប្រើប្រាស់ ឬការទិញសម្ភារ បរិក្ខារចាំបាច់បម្រើឲ្យកិច្ចការសន្តិសុខបោះឆ្នោត ដើម្បីដាក់ជូនប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ពិនិត្យស្នើសុំការអនុម័តពីរាជរដ្ឋាភិបាល។
- ចាត់ចែងប្រើប្រាស់សម្ភារបរិក្ខារ និងមធ្យោបាយគ្រប់ប្រភេទរបស់ក្រសួង/ស្ថាប័ន អង្គភាពពាក់ព័ន្ធដែលមានស្រាប់ដើម្បីបម្រើដល់កិច្ចប្រតិបត្តិការក្នុងការរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់សាធារណៈឲ្យបានល្អប្រសើរនៅគ្រប់សម័យបោះឆ្នោតនីមួយៗ ។
- ចប់ការចុះឈ្មោះបោះឆ្នោត ឬការបោះឆ្នោតនីមួយៗ ត្រូវធ្វើរបាយការណ៍ជុំវិញសភាពការណ៍សន្តិសុខបោះឆ្នោត និងសកម្មភាពការងាររបស់យន្តការ រចនាសម្ព័ន្ធ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ។

ក្នុងករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់ ជូនប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលជ្រាប ។

**ប្រការ ៣** : លេខាធិការដ្ឋានមានសិទ្ធិប្រើប្រាស់ត្រាក្រសួងមហាផ្ទៃ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។ អនុប្រធាន និងសមាជិកត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានលេខាធិការដ្ឋាន។ ប្រធានលេខាធិការដ្ឋាន អាចបង្កើតក្រុមប្រចាំការអចិន្ត្រៃយ៍ជាជំនួយការ ដើម្បីជួយការងារបច្ចេកទេស និងរដ្ឋបាល ។

**ប្រការ ៤** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គស្នងការនគរបាលជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១៦

**ប្រធានគណៈបញ្ជាសន្តិសុខអចិន្ត្រៃយ៍**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ
- ដូចប្រការ ៥
- គ្រប់សាលារាជធានី-ខេត្ត
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- យោងតាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហៅកាត់ថា "គ.ស.ហ" ដូចមានរាយនាមខាងក្រោម ៖

១- ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា ប្រធាន

| | | |
|---|---|---|
| ២- លោកជំទាវ **ខូន សុខា** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ទ្រី ត្រាយ** | អនុប្រធានលេខាធិការដ្ឋាន គជបក | អនុប្រធាន |
| ៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឌី ទិដ្ឋា** | សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក<br>តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៥- ឯកឧត្តម **ម៉ី វ៉ាន់** | សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក<br>តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម **ប៉ែន ពេជ្រសាលី** | សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក<br>តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៧- ឯកឧត្តម **គីម រ័ត្នវិសិដ្ឋ** | សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក<br>តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- ឯកឧត្តម **ចាយ ណារិទ្ធ** | អនុរដ្ឋលេខាធិការ តំណាងក្រសួងការបរទេស<br>និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩- លោកជំទាវ **សាយ សំអាត** | អគ្គលេខាធិការអង្គភាពស៊ើបការណ៍<br>ហិរញ្ញវត្ថុកម្ពុជា | សមាជិកា |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៨៦៣.....សហវ.ប្រក

# ប្រកាសរួម

# ស្តីពី

# ការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តដឹកទំនិញស្រាល

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

អនុញ្ញាតឱ្យមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត អនុវត្តប្រមូលចំណូលពីការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .–**

សម្រាប់ប្រើប្រាស់ក្នុងប្រកាសរួមនេះ វាក្យស័ព្ទខាងក្រោមមានន័យដូចតទៅ ÷

លេខចុះបញ្ជីរថយន្ត ឬ លេខចុះបញ្ជី សំដៅត្រឹមលេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាលសម្រាប់ការចេញផ្លាកលេខ និងចេញប័ណ្ណសម្គាល់ ដើម្បីកំណត់អត្តសញ្ញាណរថយន្តនីមួយៗ តែប៉ុណ្ណោះ។

ស៊េរីលេខចុះបញ្ជី សំដៅដល់សំណុំលេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល ដែលស្ថិតនៅក្នុងលំដាប់អក្សរឡាតាំងនីមួយៗ ដែលបានកំណត់ទៅតាមលំដាប់លំដោយអក្សរ។

លេខពិសេស សំដៅដល់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាលមួយចំនួន ដែលមានលក្ខណៈពិសេស ត្រូវបានកំណត់ស្របតាមការពេញនិយមនាពេលបច្ចុប្បន្នភាពរបស់អតិថិជនមួយចំនួន និងត្រូវបានជ្រើសរើសចេញពីស៊េរីលេខចុះបញ្ជីនីមួយៗ។

លេខធម្មតា សំដៅដល់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាលមួយចំនួន ដែលស្ថិតនៅក្នុងស៊េរីលេខចុះបញ្ជីនីមួយៗ មិនរាប់បញ្ចូលលេខពិសេស។

លេខចុះបញ្ជីផ្តោះស៊េរី សំដៅដល់លេខពិសេស និងលេខធម្មតា ដែលស្ថិតនៅក្នុងស៊េរីបន្តបន្ទាប់នៃស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព។ ស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព ត្រូវបានកំណត់ដោយអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន។

បំពាក់ផ្លាកលេខ សំដៅដល់ការចាប់ផ្លាកលេខភ្ជាប់ទៅនឹងរថយន្ត ដោយមានប្រើខ្មៅ និងសៀល នៅពេលម្ចាស់រថយន្តបានបំពេញបែបបទត្រឹមត្រូវ និងស្នើសុំចុះបញ្ជីរថយន្ត។

**ប្រការ៣ ._**

ការលក់លេខចុះបញ្ជីរថយន្ត ត្រូវបានបែងចែកជាបីតំបន់ ដូចខាងក្រោម ៖

- តំបន់ ១ : លេខរថយន្ត សម្រាប់ចុះបញ្ជីនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ។
- តំបន់ ២ : លេខរថយន្ត សម្រាប់ចុះបញ្ជីនៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកណ្តាល, ខេត្តកំពង់ចាម, ខេត្តបាត់ដំបង, ខេត្តសៀមរាប, ខេត្តព្រះសីហនុ និងខេត្តត្បូងឃ្មុំ។
- តំបន់ ៣ : លេខរថយន្ត សម្រាប់ចុះបញ្ជីនៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រៃវែង, ខេត្តកំពង់ធំ, ខេត្តតាកែវ, ខេត្តស្វាយរៀង, ខេត្តពោធិ៍សាត់, ខេត្តកំពង់ឆ្នាំង, ខេត្តកំពង់ស្ពឺ, ខេត្តកំពត, ខេត្តកោះកុង, ខេត្តព្រះវិហារ, ខេត្តក្រចេះ, ខេត្តរតនគិរី, ខេត្តមណ្ឌលគិរី, ខេត្តបន្ទាយមានជ័យ, ខេត្តស្ទឹងត្រែង, ខេត្តឧត្តរមានជ័យ, ខេត្តប៉ៃលិន និងខេត្តកែប។

**ប្រការ៤ ._**

លេខចុះបញ្ជីរថយន្ត ត្រូវបានកំណត់តម្លៃលក់ ដោយបែងចែកទៅតាមប្រភេទលេខពិសេស និងលេខចុះបញ្ជីផ្តោះស៊េរី ព្រមទាំងកំណត់តម្លៃទៅតាមតំបន់នីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

តម្លៃលក់លេខចុះបញ្ជីរថយន្តដែលចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ មិនទាន់គិតបញ្ចូលកម្រៃសេវាសាធារណៈដែលបានកំណត់ដោយប្រកាសរួមលេខ ០១០ សហវ.ប្រក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៥ ._**

ការលក់ ការទិញ និងការចុះបញ្ជីរថយន្ត សម្រាប់ប្រភេទលេខពិសេស និងលេខចុះបញ្ជីផ្តោះស៊េរី ត្រូវគោរពតាមលក្ខខណ្ឌចាំបាច់មួយចំនួន ដូចខាងក្រោម ៖

១- ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការ ដើម្បីទទួលបម្រើសេវាលក់លេខពិសេស និងលេខចុះបញ្ជីផ្ដោះស៊េរី ជូនអតិថិជនឱ្យបានទាន់ពេលវេលា។ ការលក់លេខពិសេស និងលេខចុះបញ្ជីផ្ដោះស៊េរី អាចធ្វើឡើងនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ នៅទីតាំងកំណត់ជាក់លាក់ណាមួយ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

២- ការលក់ និងការទិញលេខពិសេស និងលេខចុះបញ្ជីផ្ដោះស៊េរី រវាងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្ដល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងអតិថិជន មានព្រំដែនកំណត់ត្រឹមផ្ទៃក្នុងរាជធានី ខេត្តនីមួយៗ ដែលម្ចាស់រថយន្តមានអាសយដ្ឋានអចិន្ត្រៃយ៍ និងតម្រូវឱ្យចុះបញ្ជីរថយន្តនៅក្នុងរាជធានី ខេត្តនោះ តែប៉ុណ្ណោះ។

៣- រាល់ការទិញលេខពិសេស និងលេខចុះបញ្ជីផ្ដោះស៊េរី តម្រូវឱ្យអតិថិជនបង្ហាញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើម ឬ ឯកសារដែលមានតម្លៃស្មើ ដើម្បីថតចម្លងទុកជាឯកសារ, លេខទូរស័ព្ទរបស់សាមីខ្លួន និងបង់ប្រាក់ថ្លៃទិញលេខចុះបញ្ជីរថយន្តទៅតាមតម្លៃដែលបានកំណត់ ដែលមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

៤- អតិថិជនដែលបានទិញលេខពិសេស និងលេខចុះបញ្ជីផ្ដោះស៊េរី ត្រូវបំពេញបែបបទស្នើសុំចុះបញ្ជីរថយន្តឱ្យបានរួសរាន់ក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលអតិថិជនបានបង់ប្រាក់ទិញលេខចុះបញ្ជីនោះ។ ក្នុងករណីដែលអតិថិជនមានការយឺតយ៉ាវ ឬ ខកខានមិនបានចុះបញ្ជីក្នុងរយៈពេលកំណត់ ៣០(សាមសិប)ថ្ងៃ នឹងត្រូវទទួលរងការរឹបអូសលេខចុះបញ្ជីដែលបានទិញនោះ ដោយពុំមានការផ្ដល់សំណងអ្វីឡើយ ហើយក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវប្រកាសដាក់លក់លេខទាំងនោះសាជាថ្មីទៀត។

៥- ការធ្វើប័ណ្ណសម្គាល់ជូនម្ចាស់រថយន្ត ត្រូវតែផ្ទៀងផ្ទាត់ព័ត៌មានអំពីឈ្មោះ, ភេទ, អាយុ និងអាសយដ្ឋានអចិន្ត្រៃយ៍ដែលចុះក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីអតិថិជន ដែលបានរក្សាទុកនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្ដល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន នាពេលលក់ទិញលេខចុះបញ្ជីរថយន្ត។

៦- ការបំពាក់ផ្លាកលេខ ត្រូវធ្វើឡើងមិនឱ្យលើសពីរយៈពេលមួយម៉ោង បន្ទាប់ពីម្ចាស់រថយន្តបានបំពេញបែបបទស្នើសុំចុះបញ្ជីបានត្រឹមត្រូវ និងផ្ដល់ឯកសារភ្ជាប់គ្រប់គ្រាន់។

៧- ការផ្ដល់ប័ណ្ណសម្គាល់រថយន្ត ត្រូវធ្វើឡើងស្របតាមរយៈពេលផ្ដល់សេវា ដែលកំណត់ដោយប្រកាសរួមលេខ ០១០ សហវ.ប្រក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៦ .-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយនូវប្រកាសរួម និងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ។ ជាពិសេស ត្រូវផ្សព្វផ្សាយអំពីស្ថានភាពបច្ចុប្បន្នភាពនៃលេខចុះបញ្ជីទាំងអស់នៃស៊េរីលេខចុះបញ្ជីនីមួយៗដែលត្រូវដាក់លក់, លេខពិសេស និងលេខចុះបញ្ជីផ្ទោះស៊េរី ដែលអតិថិជនបានទិញរួច ដោយមានបញ្ជាក់អំពីឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់សាមីជន ព្រមទាំងលេខពិសេស និងលេខចុះបញ្ជីផ្ទោះស៊េរី ដែលនៅសល់ទំនេរ សម្រាប់ការលក់បន្ត ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន(ម្ចាស់រថយន្ត) សម្រាប់ការពិនិត្យ និងការសម្រេចចិត្តទិញយកលេខចុះបញ្ជីប្រភេទណាមួយ ដែលសាមីខ្លួនពេញចិត្ត។

បែបបទ នីតិវិធី និងលក្ខខណ្ឌ សម្រាប់ការលក់ និងការទិញលេខពិសេស និងលេខចុះបញ្ជីផ្ទោះស៊េរី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៧ .-**

រាល់ការទិញលេខពិសេស និងលេខចុះបញ្ជីផ្ទោះស៊េរី ដែលមានចែងក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ តម្រូវឱ្យអតិថិជនបង់ប្រាក់នៅធនាគារដៃគូណាមួយ តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប៉ុន្តែក្នុងករណីដែលការបង់ប្រាក់នៅធនាគារដៃគូមិនទាន់អាចប្រព្រឹត្តទៅបាន អតិថិជនត្រូវបង់ប្រាក់នៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្តសាមី ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

រាល់ការទទួលប្រាក់ចំណូលជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការលក់លេខពិសេស និងលេខចុះបញ្ជីផ្ទោះស៊េរី មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨ .-**

អនុញ្ញាតឱ្យបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីគ្រប់គ្រងការលក់លេខចុះបញ្ជីរថយន្ត ដែលកំណត់ដោយប្រកាសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ គណៈកម្មការអន្តរក្រសួងនេះ ដឹកនាំដោយតំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, តំណាងអង្គភាពប្រឆាំងអំពើពុករលួយ, តំណាងសាលារាជធានីភ្នំពេញ និងតំណាងអគ្គនាយកដ្ឋានដឹកជញ្ជូន។

**ប្រការ៩ .-**

ប្រាក់ចំណូលទាំងអស់ដែលបានមកពីការលក់លេខចុះបញ្ជីរថយន្តនៅតាមមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវកំណត់ឱ្យបង់ចូលគណនីរួមមួយ ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន។ ការបើកគណនីនៅធនាគារពាណិជ្ជណាមួយ សម្រាប់ការទទួលប្រាក់ចំណូលនេះ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការចាត់ចែងប្រាក់ចំណូលដែលបានមកពីការលក់លេខចុះបញ្ជីរថយន្ត ត្រូវអនុវត្តតាមការសម្រេចរួមរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១០ .-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបើកទូលាយដោយមានដាក់លេខទូរស័ព្ទ សារអេឡិចត្រូនិក បណ្តាញសង្គម ប្រអប់សំបុត្រ និងផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅអគ្គនាយកដ្ឋានដឹកជញ្ជូន ឬ ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬ ប្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយ ផងដែរ។

**ប្រការ១១ .-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវធ្វើរបាយការណ៍ស្តីពីការប្រមូលចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ១២ .-**

អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបូកសរុបលទ្ធផលប្រចាំខែស្តីពីស្ថានភាពនៃការលក់លេខចុះបញ្ជីរថយន្តដែលប្រព្រឹត្តទៅនៅតាមរាជធានី ខេត្ត ដាក់ជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១៥ នៃខែបន្ទាប់។

**ប្រការ១៣ .-**

ប្រភេទលេខ និងតម្លៃលក់នៃលេខពិសេស និងលេខចុះបញ្ជីផ្ទោះសើរី អាចកែប្រែបានអាស្រ័យតាមការចាំបាច់ ដែលកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសាធារណការ និងដឹកជញ្ជូន

**ស៊ុន ចាន់ថុល**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

តារាងឧបសម្ព័ន្ធភ្ជាប់ទៅនឹងប្រកាសរួមលេខ ៩៦៣........ សហវ.ប្រក ចុះថ្ងៃទី..១៩........ ខែកក្កដា ឆ្នាំ២០១៦

ស្តីពីការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល

ឯកតាគិត : រៀល

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សើរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសើរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្លោះក្នុងមួយសើរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| I | **លេខពិសេស** | | | | | | |
| ១ | លេខទាំងបួនខ្ទង់ ជាលេខដូចគ្នា | | | | | | |
| | - ៧៧៧៧, ៨៨៨៨, ៩៩៩៩ | ២០ ០០០ ០០០ | ១០ ០០០ ០០០ | ៥ ០០០ ០០០ | ២ ៥០០ ០០០ | ១ ២៥០ ០០០ | ៦២៥ ០០០ |
| | - ១១១១, ២២២២, ៣៣៣៣, ៥៥៥៥, ៦៦៦៦ | ១៦ ០០០ ០០០ | ៨ ០០០ ០០០ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ |
| | - ៤៤៤៤ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ១ ២០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ |
| ២ | មានលេខ ១៦៨ ស្ថិតនៅបីខ្ទង់ខាងចុង | | | | | | |
| | - ០១៦៨, ១១៦៨, ២១៦៨, ៣១៦៨, ៥១៦៨<br>- ៦១៦៨, ៧១៦៨, ៨១៦៨, ៩១៦៨ | ១៦ ០០០ ០០០ | ៨ ០០០ ០០០ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ |
| | - ៤១៦៨ | ៣ ២០០ ០០០ | ១ ៦០០ ០០០ | ៨០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ |
| ៣ | លេខទាំងបួនខ្ទង់ ជាលេខរៀងគ្នាតាមលំដាប់ឡើង | | | | | | |
| | - ៥៦៧៨, ៦៧៨៩ | ១០ ០០០ ០០០ | ៥ ០០០ ០០០ | ២ ៥០០ ០០០ | ១ ៥០០ ០០០ | ៧៥០ ០០០ | ៣៧៥ ០០០ |
| | - ០១២៣, ១២៣៤, ២៣៤៥, ៣៤៥៦, ៤៥៦៧ | ៦ ០០០ ០០០ | ៣ ០០០ ០០០ | ១ ៥០០ ០០០ | ១ ៥០០ ០០០ | ៧៥០ ០០០ | ៣៧៥ ០០០ |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្ទេរក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| ៤ | លេខពីរខ្ទង់ខាងដើម និងលេខពីរខ្ទង់ខាងចុង ជាលេខគូ | | | | | | |
| | - ១១២២, ១១៣៣, ១១៥៥, ១១៦៦, ១១៧៧ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ១ ២០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ |
| | - ១១៨៨, ១១៩៩, ២២១១, ២២៣៣, ២២៥៥ | | | | | | |
| | - ២២៦៦, ២២៧៧, ២២៨៨, ២២៩៩, ៣៣១១ | | | | | | |
| | - ៣៣២២, ៣៣៥៥, ៣៣៦៦, ៣៣៧៧, ៣៣៨៨ | | | | | | |
| | - ៣៣៩៩, ៥៥១១, ៥៥២២, ៥៥៣៣, ៥៥៦៦ | | | | | | |
| | - ៥៥៧៧, ៥៥៨៨, ៥៥៩៩, ៦៦១១, ៦៦២២ | | | | | | |
| | - ៦៦៣៣, ៦៦៥៥, ៦៦៧៧, ៦៦៨៨, ៦៦៩៩ | | | | | | |
| | - ៧៧១១, ៧៧២២, ៧៧៣៣, ៧៧៥៥, ៧៧៦៦ | | | | | | |
| | - ៧៧៨៨, ៧៧៩៩, ៨៨១១, ៨៨២២, ៨៨៣៣ | | | | | | |
| | - ៨៨៥៥, ៨៨៦៦, ៨៨៧៧, ៨៨៩៩, ៩៩១១ | | | | | | |
| | - ៩៩២២, ៩៩៣៣, ៩៩៥៥, ៩៩៦៦, ៩៩៧៧ | | | | | | |
| | - ៩៩៨៨ | | | | | | |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់ស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្លោះក្នុងមួយស៊េរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ០០១១, ០០២២, ០០៣៣, ០០៤៤, ០០៥៥ | | | | | | |
| | - ០០៦៦, ០០៧៧, ០០៨៨, ០០៩៩, ១១០០ | | | | | | |
| | - ១១៤៤, ២២០០, ២២៤៤, ៣៣០០, ៣៣៤៤ | | | | | | |
| | - ៤៤០០, ៤៤១១, ៤៤២២, ៤៤៣៣, ៤៤៥៥ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ |
| | - ៤៤៦៦, ៤៤៧៧, ៤៤៨៨, ៤៤៩៩, ៥៥០០ | | | | | | |
| | - ៥៥៤៤, ៦៦០០, ៦៦៤៤, ៧៧០០, ៧៧៤៤ | | | | | | |
| | - ៨៨០០, ៨៨៤៤, ៩៩០០, ៩៩៤៤ | | | | | | |
| ៥ | លេខបីខ្ទង់ខាងចុង ជាលេខដូចគ្នា | | | | | | |
| | - ០១១១, ០២២២, ០៣៣៣, ០៥៥៥, ០៦៦៦ | | | | | | |
| | - ០៧៧៧, ០៨៨៨, ០៩៩៩, ១២២២, ១៣៣៣ | | | | | | |
| | - ១៥៥៥, ១៦៦៦, ១៧៧៧, ១៨៨៨, ១៩៩៩ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ១ ២០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ |
| | - ២១១១, ២៣៣៣, ២៥៥៥, ២៦៦៦, ២៧៧៧ | | | | | | |
| | - ២៨៨៨, ២៩៩៩, ៣១១១, ៣២២២, ៣៥៥៥ | | | | | | |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខ ចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុង មួយលេខសម្រាប់ការផ្ដោះក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ៣៦៦៦, ៣៧៧៧, ៣៨៨៨, ៣៩៩៩, ៥១១១ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ១ ២០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ |
| | - ៥២២២, ៥៣៣៣, ៥៦៦៦, ៥៧៧៧, ៥៨៨៨ | | | | | | |
| | - ៥៩៩៩, ៦១១១, ៦២២២, ៦៣៣៣, ៦៥៥៥ | | | | | | |
| | - ៦៧៧៧, ៦៨៨៨, ៦៩៩៩, ៧១១១, ៧២២២ | | | | | | |
| | - ៧៣៣៣, ៧៥៥៥, ៧៦៦៦, ៧៨៨៨, ៧៩៩៩ | | | | | | |
| | - ៨១១១, ៨២២២, ៨៣៣៣, ៨៥៥៥, ៨៦៦៦ | | | | | | |
| | - ៨៧៧៧, ៨៩៩៩, ៩១១១, ៩២២២, ៩៣៣៣ | | | | | | |
| | - ៩៥៥៥, ៩៦៦៦, ៩៧៧៧, ៩៨៨៨ | | | | | | |
| | - ០៤៤៤, ១០០០, ១៤៤៤, ២០០០, ២៤៤៤ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ |
| | - ៣០០០, ៣៤៤៤, ៤០០០, ៤១១១, ៤២២២ | | | | | | |
| | - ៤៣៣៣, ៤៥៥៥, ៤៦៦៦, ៤៧៧៧, ៤៨៨៨ | | | | | | |
| | - ៤៩៩៩, ៥០០០, ៥៤៤៤, ៦០០០, ៦៤៤៤ | | | | | | |
| | - ៧០០០, ៧៤៤៤, ៨០០០, ៨៤៤៤, ៩០០០ | | | | | | |
| | - ៩៤៤៤ | | | | | | |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្លោះក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| ៦ | លេខពីរខ្ទង់ខាងដើម ជាលេខដូចគ្នានឹងលេខពីខ្ទង់ខាងចុង | | | | | | |
| | - ១២១២, ១៣១៣, ១៥១៥, ១៦១៦, ១៧១៧ | ៣ ០០០ ០០០ | ១ ៥០០ ០០០ | ៧៥០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ |
| | - ១៨១៨, ១៩១៩, ២១២១, ២៣២៣, ២៥២៥ | | | | | | |
| | - ២៦២៦, ២៧២៧, ២៨២៨, ២៩២៩, ៣១៣១ | | | | | | |
| | - ៣២៣២, ៣៥៣៥, ៣៦៣៦, ៣៧៣៧, ៣៨៣៨ | | | | | | |
| | - ៣៩៣៩, ៥១៥១, ៥២៥២, ៥៣៥៣, ៥៦៥៦ | | | | | | |
| | - ៥៧៥៧, ៥៨៥៨, ៥៩៥៩, ៦១៦១, ៦២៦២ | | | | | | |
| | - ៦៣៦៣, ៦៥៦៥, ៦៧៦៧, ៦៨៦៨, ៦៩៦៩ | | | | | | |
| | - ៧១៧១, ៧២៧២, ៧៣៧៣, ៧៥៧៥, ៧៦៧៦ | | | | | | |
| | - ៧៨៧៨, ៧៩៧៩, ៨១៨១, ៨២៨២, ៨៣៨៣ | | | | | | |
| | - ៨៥៨៥, ៨៦៨៦, ៨៧៨៧, ៨៩៨៩, ៩១៩១ | | | | | | |
| | - ៩២៩២, ៩៣៩៣, ៩៥៩៥, ៩៦៩៦, ៩៧៩៧ | | | | | | |
| | - ៩៨៩៨ | | | | | | |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | | | | | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្លោះក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ០១០១, | ០២០២, | ០៣០៣, | ០៤០៤, | ០៥០៥ | ៦០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ |
| | - ០៦០៦, | ០៧០៧, | ០៨០៨, | ០៩០៩, | ១០១០ | | | | | | |
| | - ១៤១៤, | ២០២០, | ២៤២៤, | ៣០៣០, | ៣៤៣៤ | | | | | | |
| | - ៤០៤០, | ៤១៤១, | ៤២៤២, | ៤៣៤៣, | ៤៥៤៥ | | | | | | |
| | - ៤៦៤៦, | ៤៧៤៧, | ៤៨៤៨, | ៤៩៤៩, | ៥០៥០ | | | | | | |
| | - ៥៤៥៤, | ៦០៦០, | ៦៤៦៤, | ៧០៧០, | ៧៤៧៤ | | | | | | |
| | - ៨០៨០, | ៨៤៨៤, | ៩០៩០, | ៩៤៩៤ | | | | | | | |
| ៧ | លេខបីខ្ទង់ខាងដើម ជាលេខដូចគ្នា | | | | | | | | | | |
| | - ០០០១, | ០០០៧, | ០០០៩, | ១១១២, | ១១១៦ | ២ ០០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ |
| | - ១១១៧, | ១១១៨, | ១១១៩, | ២២២៣, | ២២២៧ | | | | | | |
| | - ២២២៨, | ២២២៩, | ៣៣៣៦, | ៣៣៣៧, | ៣៣៣៨ | | | | | | |
| | - ៣៣៣៩, | ៥៥៥៦, | ៥៥៥៧, | ៥៥៥៨, | ៥៥៥៩ | | | | | | |
| | - ៦៦៦៧, | ៦៦៦៨, | ៦៦៦៩, | ៧៧៧៨, | ៧៧៧៩ | | | | | | |
| | - ៨៨៨៩, | ៩៩៩៨ | | | | | | | | | |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្លោះក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ០០០២, ០០០៣, ០០០៥, ០០០៦, ០០០៨ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ |
| | - ១១១៣, ១១១៥, ២២២១, ២២២៥, ២២២៦ | | | | | | |
| | - ៣៣៣១, ៣៣៣២, ៣៣៣៥, ៥៥៥១, ៥៥៥២ | | | | | | |
| | - ៥៥៥៣, ៦៦៦១, ៦៦៦២, ៦៦៦៣, ៦៦៦៥ | | | | | | |
| | - ៧៧៧១, ៧៧៧២, ៧៧៧៣, ៧៧៧៥, ៧៧៧៦ | | | | | | |
| | - ៨៨៨១, ៨៨៨២, ៨៨៨៣, ៨៨៨៥, ៨៨៨៦ | | | | | | |
| | - ៨៨៨៧, ៩៩៩១, ៩៩៩២, ៩៩៩៣, ៩៩៩៥ | | | | | | |
| | - ៩៩៩៦, ៩៩៩៧ | | | | | | |
| | - ០០០៤, ១១១០, ១១១៤, ២២២០, ២២២៤ | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ |
| | - ៣៣៣០, ៣៣៣៤, ៤៤៤០, ៤៤៤១, ៤៤៤២ | | | | | | |
| | - ៤៤៤៣, ៤៤៤៥, ៤៤៤៦, ៤៤៤៧, ៤៤៤៨ | | | | | | |
| | - ៤៤៤៩, ៥៥៥០, ៥៥៥៤, ៦៦៦០, ៦៦៦៤ | | | | | | |
| | - ៧៧៧០, ៧៧៧៤, ៨៨៨០, ៨៨៨៤, ៩៩៩០ | | | | | | |
| | - ៩៩៩៤ | | | | | | |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្លោះក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| ៨ | លេខនៅខ្ទង់ខាងដើម និងលេខនៅខ្ទង់ខាងចុង ជាលេខដូចគ្នា និងលេខទាំងពីរខ្ទង់នៅកណ្ដាល ជាលេខគូ | | | | | | |
| | - ១២២១, ១៣៣១, ១៥៥១, ១៦៦១, ១៧៧១ | ២ ០០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ |
| | - ១៨៨១, ១៩៩១, ២១១២, ២៣៣២, ២៥៥២ | | | | | | |
| | - ២៦៦២, ២៧៧២, ២៨៨២, ២៩៩២, ៣១១៣ | | | | | | |
| | - ៣២២៣, ៣៥៥៣, ៣៦៦៣, ៣៧៧៣, ៣៨៨៣ | | | | | | |
| | - ៣៩៩៣, ៥១១៥, ៥២២៥, ៥៣៣៥, ៥៦៦៥ | | | | | | |
| | - ៥៧៧៥, ៥៨៨៥, ៥៩៩៥, ៦១១៦, ៦២២៦ | | | | | | |
| | - ៦៣៣៦, ៦៥៥៦, ៦៧៧៦, ៦៨៨៦, ៦៩៩៦ | | | | | | |
| | - ៧១១៧, ៧២២៧, ៧៣៣៧, ៧៥៥៧, ៧៦៦៧ | | | | | | |
| | - ៧៨៨៧, ៧៩៩៧, ៨១១៨, ៨២២៨, ៨៣៣៨ | | | | | | |
| | - ៨៥៥៨, ៨៦៦៨, ៨៧៧៨, ៨៩៩៨, ៩១១៩ | | | | | | |
| | - ៩២២៩, ៩៣៣៩, ៩៥៥៩, ៩៦៦៩, ៩៧៧៩ | | | | | | |
| | - ៩៨៨៩ | | | | | | |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្ដោះក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ០១១០, ០២២០, ០៣៣០, ០៤៤០, ០៥៥០ | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ |
| | - ០៦៦០, ០៧៧០, ០៨៨០, ០៩៩០, ១០០១ | | | | | | |
| | - ១៤៤១, ២០០២, ២៤៤២, ៣០០៣, ៣៤៤៣ | | | | | | |
| | - ៤០០៤, ៤១១៤, ៤២២៤, ៤៣៣៤, ៤៥៥៤ | | | | | | |
| | - ៤៦៦៤, ៤៧៧៤, ៤៨៨៤, ៤៩៩៤, ៥០០៥ | | | | | | |
| | - ៥៤៤៥, ៦០០៦, ៦៤៤៦, ៧០០៧, ៧៤៤៧ | | | | | | |
| | - ៨០០៨, ៨៤៤៨, ៩០០៩, ៩៤៤៩ | | | | | | |
| ៩ | លេខពីរខ្ទង់ខាងចុងស្មើនឹងលេខពីរខ្ទង់ខាងដើមបូក ១ | | | | | | |
| | - ១២១៣, ១៥១៦, ១៦១៧, ១៧១៨, ១៨១៩ | ៦០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ |
| | - ២១២២, ២៥២៦, ២៦២៧, ២៧២៨, ២៨២៩ | | | | | | |
| | - ៣១៣២, ៣២៣៣, ៣៥៣៦, ៣៦៣៧, ៣៧៣៨ | | | | | | |
| | - ៣៨៣៩, ៥១៥២, ៥២៥៣, ៥៦៥៧, ៥៧៥៨ | | | | | | |
| | - ៥៨៥៩, ៦១៦២, ៦២៦៣, ៦៥៦៦, ៦៧៦៨ | | | | | | |
| | - ៦៨៦៩, ៧១៧២, ៧២៧៣, ៧៥៧៦, ៧៦៧៧ | | | | | | |
| | - ៧៨៧៩, ៨១៨២, ៨២៨៣, ៨៥៨៦, ៨៦៨៧ | | | | | | |
| | - ៨៧៨៨, ៩១៩២, ៩២៩៣, ៩៥៩៦, ៩៦៩៧ | | | | | | |
| | - ៩៧៩៨, ៩៨៩៩ | | | | | | |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្តោះក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ០១០២, ០២០៣, ០៣០៤, ០៤០៥, ០៥០៦ | ១២០ ០០០ | ៦០ ០០០ | ៣០ ០០០ | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ |
| | - ០៦០៧, ០៧០៨, ០៨០៩, ១០១១, ១៣១៤ | | | | | | |
| | - ១៤១៥, ២០២១, ២៣២៤, ២៤២៥, ៣០៣១ | | | | | | |
| | - ៣៤៣៥, ៤០៤១, ៤១៤២, ៤២៤៣, ៤៣៤៤ | | | | | | |
| | - ៤៥៤៦, ៤៦៤៧, ៤៧៤៨, ៤៨៤៩, ៥០៥១ | | | | | | |
| | - ៥៣៥៤, ៥៤៥៥, ៦០៦១, ៦៣៦៤, ៦៤៦៥ | | | | | | |
| | - ៧០៧១, ៧៣៧៤, ៧៤៧៥, ៨០៨១, ៨៣៨៤ | | | | | | |
| | - ៨៤៨៥, ៩០៩១, ៩៣៩៤, ៩៤៩៥ | | | | | | |
| ១០ | លេខពីរខ្ទង់ខាងចុង ជាលេខគូ | | | | | | |
| | - ..១១, ..២២, ..៣៣, ..៥៥, ..៦៦, | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ |
| | - ..៧៧, ..៨៨, ..៩៩ | | | | | | |
| ១១ | លទ្ធផលខ្ទង់រាយនៃផលបូកលេខទាំងបួនខ្ទង់ (ក្រៅពីលេខពិសេសដែលបានកំណត់ខាងលើ) ÷ | | | | | | |
| | - ជាលេខ ៧ ឬ ជាលេខ ៨ ឬ ជាលេខ ៩ | ១០០ ០០០ | ៥០ ០០០ | ២៥ ០០០ | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ |
| | - ជាលេខ ៦ | ៨០ ០០០ | ៤០ ០០០ | ២០ ០០០ | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ |
| II | **លេខធម្មតា** | មិនគិតថ្លៃ | | | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ |

ទំព័រ ១០ នៃ ១០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៨៦៤ សហវ.ប្រក

## ប្រកាសរួម
## ស្តីពី
## ការគ្រប់គ្រងចំណូលពីការលក់លេខចុះបញ្ជីរថយន្ត

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ៨៦៣ សហវ.ប្រក ចុះថ្ងៃទី.១៩.. ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ លើលិខិតរួមចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីការរៀបចំប្រកាសរួម ដើម្បីប្រមូលចំណូលពីការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល។

## សម្រេច

**ប្រការ១ .–**

ប្រគល់សិទ្ធិជូនអគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន(អគ្គនាយកដ្ឋានដឹកជញ្ជូន) ទទួលខុសត្រូវលើការគ្រប់គ្រងប្រាក់ចំណូលប្រមូលបានពីការលក់លេខចុះបញ្ជីរថយន្ត ដែលកំណត់ដោយប្រកាសរួមលេខ.៨៦៣ សហវ.ប្រក ចុះថ្ងៃទី.១៩.. ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល។

**ប្រការ២ .–**

អនុញ្ញាតឱ្យអគ្គនាយកដ្ឋានដឹកជញ្ជូន បើកគណនីប្រាក់បញ្ញើជាប្រាក់រៀលនៅធនាគារឯកទេសរីង ឬធនាគារពាណិជ្ជណាមួយ ដើម្បីប្រមូលផ្តុំប្រាក់ចំណូលពីការលក់លេខចុះបញ្ជីរថយន្ត នៅទូទាំងរាជធានី ខេត្ត ទាំង ២៥ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .–**

អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវធ្វើសេចក្តីជូនដំណឹងឱ្យបានច្បាស់លាស់ដល់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងអតិថិជន ស្តីពីការបង់ប្រាក់ និងការទទួលប្រាក់ថ្លៃទិញលេខចុះបញ្ជីរថយន្ត ដែលត្រូវធ្វើឡើងនៅតាមមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ឬ តម្រូវឱ្យអតិថិជនបង់ប្រាក់ចូលគណនីនៅធនាគារឯកទេសរីង ឬ ធនាគារពាណិជ្ជណាមួយ ដែលបានកំណត់។

**ប្រការ៤ .–**

អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលស្តីពីការអនុវត្តចំណូលប្រចាំខែ គោរពជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១៥ នៃខែបន្ទាប់ ដោយភ្ជាប់ជាមួយរបាយការណ៍របស់ធនាគារឯកទេសរីង ឬ ធនាគារពាណិជ្ជ។

**ប្រការ៥ .–**

រាល់ការចាត់ចែងប្រាក់ចំណូលដែលប្រមូលបានពីការលក់លេខចុះបញ្ជីរថយន្ត ត្រូវអនុវត្តតាមនីតិវិធីដូចតទៅ ÷

ក- ផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូលជាក់ស្តែងប្រចាំត្រីមាសនីមួយៗ អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវធ្វើសំណើសុំគោលការណ៍សម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការអនុវត្តលើមុខចំណាយដូចខាងក្រោម ÷

